- យើងតំរៀបវាតាមប្រភេទលេខរបស់វា (លេខ ១, ២ និង ៣) ដោយដាក់មើមរបស់វាផ្ទុយគ្នា ដើម្បីងាយស្រួលក្នុងការរៀប ហើយអាចដាក់ចំណុះបានច្រើន
- ការដឹកជញ្ជូន គួរប្រើឡាន ឬទូកដែលមានចំណុះច្រើន ហើយធ្វើយ៉ាងណាកុំដាក់កញ្ជ្រែលើគ្នាដោយផ្ទាល់ ត្រូវតំរៀបជាថ្នាក់ៗ
- ក្នុងពេលធ្វើដំណើរឡាន ឬទូក ត្រូវមានដំបូលការពារកំដៅថ្ងៃ និងធូលី។





## ៥) ការស្តុកទុក

ប្រសិនបើយើងដកភ្លាមយកទៅប្រើប្រាស់ភ្លាមៗ យើងអាចលាងទឹកមើមបាន។ ប៉ុន្តែការលាងទឹកមិនអាចធ្វើឱ្យយើងរក្សាទុកបានយូរទេ គឺបានត្រឹមតែ ១ ទៅ ២ ថ្ងៃប៉ុណ្ណោះ លើសពីនេះវាអាចខូចគុណភាព ដោយធ្វើឱ្យមើមរលួយ ឬស្មោគពីខាងក្នុង។ ដោយឡែក គេអាចរក្សាទុកឆៃថាវបានរយៈពេល ៧ ថ្ងៃ ដោយ យកដីខ្សាច់ក្រាលនៅបាតកញ្ជ្រែ (យកកញ្ជ្រែដែលមានប្រហោងខ្យល់ចេញចូល) កំរាស់ ១ តឹក ។

បន្ទាប់មកយកមើមឆៃថាវដែលបានប្រមូលផល និងសំអាតរួចទៅតំរៀបដាក់ពីលើដីខ្សាច់កំពស់ ៤ តឹក ទើបយកក្រណាត់ដែលជក់ទឹកជ្រលក់ទឹកឱ្យសើមៗ គ្របពីលើ។ បើក្រណាត់ស្ងួត យើងត្រូវបាញ់ទឹកផ្សើមក្រណាត់ឱ្យជាប់ជានិច្ច។ ការធ្វើបែបនេះ យើងអាចរក្សាទុកបានរហូតដល់ ៧ ថ្ងៃ ដោយមិនខូចគុណភាព។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

របស់ ប៊ុនលី និង ឌុល វណ្ណនី

# វិធីសាស្ត្រគ្រប់គ្រង ឆៃថាវ

## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

- ជាទូទៅផ្លែថាវមានរយៈពេលលូតលាស់ ៤០ ទៅ ៤៥ ថ្ងៃ ទើបអាចប្រមូលផលបាន។
- ចំពោះការប្រមូលផល យើងត្រូវពិនិត្យទៅលើអាយុកាលនៃការដុះលូតលាស់របស់វា បើដល់អាយុហើយ យើងត្រូវពិនិត្យទៅលើលក្ខណៈដងដើមរបស់វាទៀត ដោយឃើញវាឡើងលើដីធំល្មម។
- ការប្រមូលផល គឺត្រូវធ្វើឡើងដោយដៃ ចាប់ដកដើមពីក្នុងថ្នាលតែម្តង បើដីថ្នាលនោះផុសល្អ
- ម្យ៉ាងទៀត វិធីល្អបំផុតយើងត្រូវប្រើដៃដែក ចបចក់ដែលមានធ្មេញវែងៗ គាស់វាជាមុនសិនទើបប្រមូលតាមក្រោយជាការល្អ



- កុំស្រោចទឹក ១ ថ្ងៃមុនពេលប្រមូលផល
- យើងអាចធ្វើការប្រមូលផលនៅពេលស្ងួតល្អ ជៀសវាងការប្រឡាក់ ដើម្បីជៀសវាងការឆ្លងជំងឺសំខាន់គឺផ្សិតដែលបណ្តាលឱ្យផ្លែថាវឆាប់ស្អោត
- ពេលដកភ្លាមត្រូវដឹកជញ្ជូនចូលម្លប់ភ្លាម។

## ២) ការសំអាត និងតំរឹម

- ផ្លែថាវក្រោយពីដករួច គឺមិនត្រូវលាងទឹកទេ ពីព្រោះបើលាងវានាំឱ្យឆាប់រលួយ និងស្អោតសាច់ផ្នែកខាងក្នុង
- ការសំអាត គឺគ្រាន់តែបេះដីណាដែលជាប់ធំពេកនៅលើមើមតែប៉ុណ្ណោះ តែមិនត្រូវឱ្យវាជ្រះពេកទេ គឺទុកវាខ្លះដើម្បីការពារសំណើម និងសំបកកុំឱ្យវារលាក
- ការតំរឹម គឺយើងកាត់តែឫសកែវ ឬឫសស្វៃវែងៗ ដែលជាប់មើមរបស់វាចេញ និងកាត់ស្លឹករបស់វាដោយទុកចំងាយពីមើមប្រហែល ១ តឹក។





## ៣) ការជ្រើសរើស

ក្រោយពីប្រមូលផល និងកាត់ដើមឫសចេញ ហើយ យើងត្រូវរៀបចែកវាជា ៣ ប្រភេទ គឺប្រភេទលេខ ១ ជ្រើសរើសមើមធំដាក់ម្ខាំ និងទី ២ មើមធំល្មម និងទី ៣ មើមដែលមានខ្នែង ឬមានប៉ះទង្គិចបាក់បែក ដើម្បីយកទៅប្រើប្រាស់ភ្លាមៗ (កែច្នៃធ្វើជាផ្លែប៉ូវជាដើម)។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

- ក្រោយពីសំអាត និងជ្រើសរើសរួចមក យើងអាចយកវាទៅតំរៀបក្នុងកញ្ជេដែលមានទ្រាប់ស្លឹកចេក ឬស្លឹករុក្ខជាតិផ្សេងទៀតនៅបាត និងហ៊ុំជុំវិញ
- ក្នុងការដាក់វាទៅក្នុងកញ្ជេ គួររក្សាវាឱ្យនៅមានដីខ្លះៗនៅជាប់មើមរបស់វា បើមិនដូចនេះទេយើងយកដីខ្សាច់មករោយចន្លោះមើមដែលបានរៀបរួច ដើម្បីរក្សាសំណើម និងកាត់បន្ថយការប៉ះទង្គិ